# អង្គការគោលដៅយុត្តិធម៌
# ការពិពណ៌នាអំពីការងារ - ជំនួយការហាងកាហ្វេយុត្តិធម៌

## អំពីហាងកាហ្វេយុត្តិធម៌

ការផុងកាហ្វេនិងគំនិតគឺជាក្តីសុបិន្ត ហើយវាបានក្លាយជាការពិត។

ដោយមានបំណងដើម្បីផ្តល់នូវកន្លែងដែលមានសុវត្ថិភាព និងការចូលរួម សម្រាប់អ្នកផ្លាស់ប្តូរវ័យក្មេង យើងបានបើកហាងកាហ្វេយុត្តិធម៌នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៥ ដោយមានការគាំទ្រពី CFIDEV ។

ហាងកាហ្វេយុត្តិធម៌គឺជាគម្រោងសំខាន់មួយរបស់អង្គការគោលដៅយុត្តិធម៌ ដោយវាជាផ្នែកមួយនៃកម្មវិធី “យុត្តិធម៌មានសារៈសំខាន់នៅកម្ពុជា”។ អង្គការគោលដៅយុត្តិធម៌ គឺជាអង្គការមិនរកប្រាក់ចំណេញដែលបានចុះបញ្ជីជាអង្គការក្នុងស្រុកមួយនៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ២០១៣ ដែលធ្វើការឆ្ពោះទៅរកពិភពលោកដែលមានយុត្តិធម៌ប្រសើរជាងមុន ដោយការបង្កើតការផ្លាស់ប្តូរប្រកបដោយចីរភាព។

តាំងពីបង្កើតឡើងមក ហាងកាហ្វេយុត្តិធម៌ បានរីកចម្រើនទៅជាផ្ទះមួយសម្រាប់អ្នកផ្លាស់ប្តូរ ជាមួយនឹងធនធានជាច្រើនដែលអាចរកបាន ដូចជាសៀវភៅគ្រប់ប្រភេទ និងស្ទូឌីយោថត ជាដើម។ ដោយមានការរៀបចំដោយក្រុមការងាររបស់យើង ហាងកាហ្វេយុត្តិធម៌យុត្តិធម៌ក៏ជាកន្លែងសម្រាប់ ព្រឹត្តិការណ៍ជាច្រើនដូចជា កិច្ចពិភាក្សាកាហ្វេ និងកម្មវិធីបណ្តុះបណ្តាលអ្នកផ្លាស់ប្តូរ ជាដើម។ មិនតែប៉ុណ្ណោះ យើងក៏កំពុងបោះពុម្ពផ្សាយសៀវភៅដោយខ្លួនឯង និងផលិតខ្សែភាពយន្តឯកសារ និងវីដេអូអប់រំជាច្រើន។

ក្នុងនាមជាសហគ្រាសសង្គម ហាងកាហ្វេយុត្តិធម៌ មានមោទនភាពក្នុងការក្លាយជាហាងកាហ្វេសម្រាប់អ្នកស្រលាញ់ភេទដូចគ្នា ក្នុងការទិញផលិតផលរបស់ខ្លួនពីសហគ្រាសសង្គមផ្សេងៗទៀត ដូចជា Tree Corner Coffee និងក្នុងការការលើកកម្ពស់គំនិតផ្តួចផ្តើមមិនប្រើប្រាស់ផ្លាស់ស្ទិច។

## ការពិពណ៌នាអំពីការងារ

### ការចូលរួម

**តួនាទី៖** ជំនួយការអ្នកគ្រប់គ្រង

**រយៈពេលសរុប៖** ៦ខែ ពេញម៉ោង (៤៨ម៉ោង/សប្តាហ៍) ជាមួយនឹងលទ្ធភាពក្នុងការបន្តកិច្ចសន្យាការងារដោយអាស្រ័យលើការអនុវត្តការងារកន្លងមក

**ថ្ងៃចាប់ផ្តើម៖** ថ្ងៃច័ន្ទ ទី១០ ខែកញ្ញា ឆ្នាំ២០១៨ (ជាមួយនឹងរយៈពេលសាកល្បងពីថ្ងៃទី១ ដល់ថ្ងៃទី១៦ ខែសីហា)

**ប្រាក់ខែសរុប៖** ពី១៨០ ដុល្លា ទៅ ២០០ ដុល្លា ដោយអាស្រ័យលើបទពិសោធន៍ ហើយលទ្ធភាពនៃការតម្លើងប្រាក់ខែអាស្រ័យលើការអនុវត្តការងារ
**អត្ថប្រយោជន៍៖** របបសន្តិសុខសង្គម ថ្ងៃឈប់សម្រាកសាធារណៈទាំងអស់ និងបន្ថែមថ្ងៃឈប់សម្រាក ១,៥ ថ្ងៃក្នុងមួយខែ និងការបញ្ចុះតម្លៃ ៥០% លើការទិញភេសជ្ជៈនៅហាងកាហ្វេ។

## ទីកន្លែង

ហាងកាហ្វេយុត្តិធម៌ របស់អង្គការគោលដៅយុត្តិធម៌ ក្នុងរាជធានីភ្នំពេញ

## ការរំពឹងទុក

**ការរំពឹងទុកចំបង៖ ការដំណើរការប្រចាំថ្ងៃរបស់ហាងកាហ្វេយុត្តិធម៌ និងមជ្ឈមណ្ឌល**

១. ជាទូទៅ ចូរធ្វើតាមតម្រូវការការងារជាមូលដ្ឋាន (ឧ. ឯកសណ្ឋាន និងភាពទាន់ពេលវេលា); យល់អំពី "វិធី" និង "មូលហេតុ" នៃគោលនយោបាយនិងនីតិវិធីរបស់កាហ្វេយុត្តិធម៌; លើកកម្ពស់ការងារជាក្រុមដើម្បីសម្រេចបាននូវគោលដៅរបស់ហាងកាហ្វេ ដើម្បីឲ្យការងារដែលត្រូវបានផ្តល់ឲ្យ ត្រូវបានធ្វើឡើងដោយទាន់ពេលវេលា; អនុវត្តតាមការណែនាំសមស្របទាំងអស់ដែលផ្តល់ដោយអ្នកគ្រប់គ្រង; សូមស្វាគមន៍រាល់អតិថិជនទាំងអស់ដោយស្នាមញញឹម និងមានភាពស្និទ្ធស្នាលគ្រប់ពេលវេលា; ផ្តោតចម្បងលើការបំពេញតម្រូវការរបស់អតិថិជន និងព្យាយាមឆ្លើយតបទៅ ការសាកសួរធម្មតារបស់អតិថិជន និងផ្ទេរការសាកសួរផ្សេងៗទៀតរបស់អតិថិជនទៅអ្នកគ្រប់គ្រង; ត្រូវដឹងអំពីគោលដៅនៃហាងកាហ្វេ និងធានាឲ្យបាននូវសកម្មភាពផ្សេងៗដើម្បីរួមចំណែកដល់សមិទ្ធផលទាំងអស់; ថែរក្សាទីតាំងប្រតិបត្តិការ និងផ្ទះបាយ ដើម្បីឆ្លើយតបនឹងអនាម័យ ផាសុខភាព និងភាពជឿជាក់របស់អតិថិជន; ធានាថាទំនិញមានគ្រប់គ្រាន់ ហើយប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានកត់ត្រាទុក។
២. ជាពិសេស អនុវត្តនីតិវិធីហាងកាហ្វេយុត្តិធម៌ រួមទាំងការរៀបចំ និងការបម្រើភេសជ្ជៈ និងអាហារសម្រាប់អតិថិជន។
៣. ជួយក្នុងការគ្រប់គ្រងមជ្ឈមណ្ឌលយុត្តិធម៌ក្នុងការរក្សាទំនាក់ទំនងល្អជាមួយអ្នកស្នាក់នៅ ប្រមូលថ្លៃជួល និងស្វែងរកដំណោះស្រាយប្រសិនបើ / នៅពេលមានបញ្ហាកើតឡើង។
៤. ជួយអ្នកគ្រប់គ្រងហាងកាហ្វេយុត្តិធម៌និងបណ្ណាល័យ នៅក្នុងការគ្រប់គ្រងប្រចាំថ្ងៃរបស់ហាងកាហ្វេ ដូចជា ផ្នែករដ្ឋបាលនិងគណនេយ្យជាដើម។

**ការរំពឹងទុកផ្សេងទៀត៖**

១. នៅពេលត្រូវការ សូមចូលរួមនិងជួយសមាជិកក្រុមផ្សេងទៀត ក្នុងការបំពេញភារកិច្ចផ្សេងៗ ដែលទាក់ទងទៅនឹងកម្មវិធីផ្សេងទៀតរបស់អង្គការ។
២. ចូលរួមក្នុងកម្មវិធីផ្សេងៗរបស់អង្គការ។

## លក្ខណៈសម្បត្តិដែលចង់បាន៖

យើងកំពុងស្វែងរកអ្នកដែល៖

- បំពេញភារៈកិច្ចបានទាន់ពេលវេលា

- មាន "គំនិតផ្តួចផ្តើម" "ភាពច្នៃប្រឌិត" "ភាពវៃឆ្លាត"
- អាចបង្កើតទំនាក់ទំនងជាមួយមនុស្សដែលមានវប្បធម៌ផ្សេងប្រកបដោយប្រសិទ្ធភាព
- អាចសម្របខ្លួនបាន ជាពិសេសនៅក្នុងស្ថានភាពលំបាក

## ជំនាញដែលចង់បាន៖

យើងកំពុងស្វែងរកអ្នកដែល:

- មិនភ័យខ្លាចក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ (ឧ. ធ្លាប់មានបទពិសោធន៍នៅក្នុងឧស្សាហកម្មបម្រើម្ហូបអាហារដូចជា McDonalds ឬកន្លែងផ្សេងទៀត កាន់តែប្រសើរ)
- មានគំនិតដោះស្រាយបញ្ហា ហើយមិនខ្លាចនឹងសួរសំណួរនៅពេលចង់ដឹង
- ធ្វើការក្នុងក្រុមបានល្អ
- មានឥរិយាបថប្រកបដោយវិជ្ជាជីវៈ
- មានរបៀបរៀបរយ និងមិនទទួលបានការរំខានដោយងាយៗ

## ប្រវត្តិរូបដែលចង់បាន៖

យើងកំពុងស្វែងអ្នកដែល:

- មានបទពិសោធន៍ធ្វើការនៅក្នុងហាងកាហ្វេ និងបទពិសោធន៍សហគ្រិនភាព កាន់តែប្រសើរ
- ជាជនជាតិខ្មែរដែលមានចំនេះដឹងភាសាអង់គ្លេស

សូមដាក់ពាក្យសុំរបស់អ្នកនៅឯ careers@destintejustice.org មុនថ្ងៃពុធ ទី២៥ ខែកក្កដា ម៉ោង ៥ រសៀល។

អង្គការគោលដៅយុត្តិធម៌ គឺជានិយោជកដែលផ្តល់ឱកាសការងារស្មើភាពគ្នា។ ការសម្រេចចិត្ត រួមទាំងការជ្រើសរើសបុគ្គលិក ត្រូវបានធ្វើឡើងដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ សាសនា ភេទ ជាតិកំណើត ពូជពង្ស អាយុ ពិការភាព ឬការចាត់ថ្នាក់ណាមួយផ្សេងទៀតដែលត្រូវបានការពារដោយច្បាប់។